# ឧបសម្ព័ន្ធ ២

នៃអនុក្រឹត្យលេខ ២០៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែ ធ្នូ..... ឆ្នាំ ២០០៧

## សេចក្តីពន្យល់ និងកំណត់សម្គាល់សម្រាប់ការអនុវត្ត បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

### I- និយមន័យ ៖

ទំនិញជាប់អាយ័ត និងទំនិញជាប់កម្រិតកំណត់គឺជាទំនិញដែលស្ថិតក្រោមល័ក្ខខ័ណ្ឌលើការនាំចេញ ឬនាំចូលក្នុងគោលបំណងណាមួយដូចជា ៖

- ការការពារសន្តិសុខជាតិ
- ការការពារសណ្តាប់ធ្នាប់សាធារណៈ និងស្តង់ដារនៃសុភាវធម៌ និងសីលធម៌
- ការការពារសុខភាព និងជីវិតមនុស្ស សត្វ ឬរុក្ខជាតិ
- ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬបុរាណវត្ថុវិទ្យា
- ការអភិរក្សធនធានធម្មជាតិ
- ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ ។

បញ្ជីទំនិញនេះត្រូវកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ស្របតាមបញ្ញត្តិនៃមាត្រា ៨ នៃច្បាប់ស្តីពីគយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ។

ការនាំចេញ ឬនាំចូលទំនិញក្នុងបញ្ជីនេះជាកម្មវត្ថុនៃ ៖

- ការហាមឃាត់ដាច់ខាតមិនឲ្យធ្វើការនាំចេញ ឬនាំចូល
- ការអនុញ្ញាតឲ្យនាំចេញ ឬនាំចូលដោយតម្រូវឲ្យមានអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ឬវិញ្ញាបនប័ត្រផ្សេងៗ ព្រមទាំងឯកសារគតិយុត្តិដែលមានទម្រង់ប្រហាក់ប្រហែលជាមុន ឬស្ថិតក្រោមប្រព្រឹត្តិកម្មដោយឡែកមួយចំនួនពីអាជ្ញាធរមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលរួមមាន ក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចពាក់ព័ន្ធស្របតាមច្បាប់ ឬបទប្បញ្ញត្តិនានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

### II- កំណត់សំគាល់៖

១- បញ្ជីនេះមិនអនុវត្តចំពោះការនាំចេញ ឬនាំចូលដែលគ្មានលក្ខណៈពាណិជ្ជកម្មតាមរូបភាពជា ទំនិញគំរូ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកធ្វើដំណើរ សម្ភារៈផ្លាស់ប្តូរលំនៅដ្ឋាន ឬតាមរូបភាពប្រហាក់ប្រហែល ។ ការលើកលែងនេះ មិនអនុវត្តចំពោះមុខ

ទំនិញដែលស្ថិតក្រោមមុខសញ្ញាហាមឃាត់ដាច់ខាតក្នុងការនាំចេញ នាំចូល ឬប្រភេទមានហានិភ័យខ្ពស់ដល់សុវត្ថិភាពសាធារណៈ។

២- ផលិតផលមានដើមកំណើតពីសត្វដែលស្ថិតក្នុងបញ្ជីសាយតេស ប៉ុន្តែមិនមានបញ្ជាក់ច្បាស់ក្នុងតារាងនេះដោយហេតុផលបច្ចេកទេសនោះ ត្រូវមានលិខិតអនុញ្ញាតសាយតេស។

៣- ដោយសារហេតុផលបច្ចេកទេសនៃតារាងពន្ធគយ បញ្ជីនេះមិនបានដាក់បញ្ចូលនូវមុខទំនិញជាប់អាយ៉ត និងទំនិញជាប់កម្រិតកំណត់ដូចខាងក្រោម៖

- វេយន្តចង្កូតស្តាំ
- ទំនិញប្រើរួចមួយចំនួនដូចជា កំព្យូទ័រ ស្បែកជើង កាបូប អាគុយ ជាដើម
- សៀវភៅសាសនា សៀវភៅនយោបាយ រូបភាពអាសអាភាស រូបភាពពាណិជ្ជកម្ម និងឯកសារបោះពុម្ពដែលច្បាប់ហាមឃាត់ផ្សេងទៀត
- ទំនិញល្មើសច្បាប់កម្មសិទ្ធិបញ្ញា (IPR Law) ឬទំនិញក្លែងក្លាយ និងទំនិញល្មើសសិទ្ធិផ្តាច់មុខ

៤- បរិក្ខា ឬឧបករណ៍បច្ចេកទេសបម្រើឲ្យការហោះហើរ ត្រូវមានការឯកភាពជាមុនពីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល។

៥- ឧបករណ៍ត្រជាក់ប្រភេទប្រើរួចគ្រប់ប្រភេទ ឬប្រភេទថ្មីដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន ត្រូវមានការអនុញ្ញាតឲ្យនាំចូលពីក្រសួងបរិស្ថាន។

៦- ទំនិញនាំចូលត្រូវគោរពតាមវិធានស្តង់ដារឧស្សាហកម្មកម្ពុជា និងវិធានគុណភាព និងសុវត្ថិភាព

៧- ចំពោះពូជដំណាំ ឬគ្រាប់ពូជផ្សេងទៀតដែលពុំមានចែងក្នុងបញ្ជីនេះ ត្រូវទទួលនូវប្រព្រឹត្តកម្មដូចគ្នាជាមួយពូជដំណាំ ឬគ្រាប់ពូជក្នុងបញ្ជីនេះដែរ ស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងសម្ភារៈកសិកម្ម។

៨- ចំពោះប្រភេទទំនិញនាំចេញណា ដែលប្រទេសនាំចូលតម្រូវឲ្យមានវិញ្ញាបនប័ត្របញ្ជាក់សុខភាពសត្វ វិញ្ញាបនប័ត្រភូតគាមអនាម័យ វិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រផលផល ឬវិញ្ញាបនប័ត្រផ្សេងៗទៀត អ្នកនាំចេញត្រូវស្នើសុំវិញ្ញាបនប័ត្រទាំងនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ចដទៃទៀត ស្របតាមការតម្រូវនៃប្រទេសនាំចូលនោះ។

៩- ចំពោះការនាំចេញធនធានរ៉ែ ត្រូវមានការអនុញ្ញាតិឲ្យនាំចេញពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

១០- ចំពោះទំនិញក្នុងជំពូកទី ២៨ និងជំពូកទី ២៩ ណាដែលជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ និង/ឬដែលមានចែងក្នុងបញ្ជីនៃសារធាតុផ្សំគ្រឿងញៀន បញ្ជីនៃសារធាតុប៉ះពាល់ដល់សរសៃប្រសាទ និងបញ្ជីគ្រឿងញៀន ត្រូវមានលិខិតអនុញ្ញាតពីក្រសួងសុខាភិបាល ។ ដោយឡែកចំពោះទំនិញក្នុងជំពូកទី ២៨ និងជំពូកទី ២៩ ណាដែលពុំមានចែងក្នុងបញ្ជីទាំងបីនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

១១- ចំពោះបសុឱសថដែលពុំមានចែងច្បាស់លាស់នៅក្នុងបញ្ជីនេះ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១២- ប្រសិនបើមានការអនុញ្ញាតឲ្យនាំចេញ ឬនាំចូលពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការនាំចេញ ឬនាំចូលអាចធ្វើទៅបាន ដោយពុំចាំបាច់មានការអនុញ្ញាតពីក្រសួង ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតឡើយ លើកលែងតែទំនិញដែលស្ថិតក្រោមកម្រិតកំណត់នៃការដឹកជញ្ជូន ដោយហេតុផលសន្តិសុខ និងសុវត្ថិភាពសាធារណៈ ។

១៣- យោងតាមសំណូមពរនៃការគ្រប់គ្រង ត្រួតពិនិត្យជាក់ស្តែង ការធ្វើវិមជ្ឈការការងារ និងលទ្ធភាពនៃប្រព័ន្ធតភ្ជាប់ព័ត៌មាន ទំនិញក្នុងបញ្ជីនេះ ដែលទទួលបានការអនុញ្ញាតឲ្យនាំចេញ ឬនាំចូលរួចហើយពីក្រសួង ស្ថាប័នមានសមត្ថកិច្ច តាមរូបភាពជាកញ្ចប់សម្រាប់ការនាំចេញ ឬនាំចូលច្រើនដង និង/ឬតាមមាត់ច្រកលើសពីមួយ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យដោយឡែកជាបណ្តោះអាសន្នពីទីចាត់ការគយ និងរដ្ឋាករ និង/ឬពីនាយកដ្ឋានកាំកុងត្រូល ។

## III- លេខសំគាល់ប្រព្រឹត្តកម្ម:

(1) : ត្រូវបំពេញបែបបទនាំចេញ-នាំចូលតាមនីតិវិធីជាធរមាន ដោយគ្រាន់តែតម្រូវឲ្យតម្កល់ឯកសាររដ្ឋបាលតែមួយ (Single Administrative Document – SAD) នៅពេលបំពេញបែបបទនាមាត់ច្រកនាំចេញ ឬនាំចូលតែម្តង និងមានឯកសារភ្ជាប់ជាមួយឯកសាររដ្ឋបាលតែមួយរួមមាន វិក្កយប័ត្រពាណិជ្ជកម្ម ឯកសារដឹកជញ្ជូន បញ្ជីវេចខ្ចប់ និងឯកសារចាំបាច់ផ្សេងទៀតប្រសិនបើមានការតម្រូវ និងពុំតម្រូវឲ្យមានការអនុញ្ញាតជាមុននាពេលនាំចេញ ឬនាំចូលឡើយ លើកលែងតែទំនិញនេះស្ថិតក្រោមរបបលើកលែង ឬព្យួរទាំងស្រុង ឬជាភាគនៃពន្ធ និងអាករ ឬរបបអនុគ្រោះផ្សេងទៀត ។

(2) : ត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតឲ្យនាំចូល ឬលិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននេះ ។

(3) : ត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតឲ្យនាំចេញ ឬលិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននេះ។

(4) : ត្រូវបានហាមឃាត់ដាច់ខាតសម្រាប់ការនាំចូល

(5) : ត្រូវបានហាមឃាត់ដាច់ខាតសម្រាប់ការនាំចេញ

(6) : ត្រូវបានហាមឃាត់ដាច់ខាតទាំងការនាំចេញ និងនាំចូល

(7) : ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាពសត្វតាមការតម្រូវរបស់ប្រទេសនាំចូល

(8) : ត្រូវមានវិញ្ញាបនប័ត្រភូតគាមអនាម័យតាមការតម្រូវរបស់ប្រទេសនាំចូល

(9) : ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផលរបស់ប្រទេសនាំចេញ

## IV– របៀបអានបញ្ជីនេះ ៖

១- អក្សរកាត់៖

| | |
|---|---|
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIMIE | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MOC | ក្រសួងពាណិជ្ជកម្ម |
| MOCFA | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| MOD | ក្រសួងការពារជាតិ |
| MOE | ក្រសួងបរិស្ថាន |
| MOH | ក្រសួងសុខាភិបាល |
| MOI | ក្រសួងមហាផ្ទៃ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| SAD | ឯកសាររដ្ឋបាលតែមួយ |

២- ត្រូវពិនិត្យមើលថាតើលេខសំគាល់ប្រព្រឹត្តកម្មនោះ ស្ថិតនៅក្នុងជួរឈរដែលមានឈ្មោះ ក្រសួង ស្ថាប័នជំនាញពាក់ព័ន្ធណា ។

ឧទាហរណ៍ ៖ បើលេខ (2) ស្ថិតនៅក្នុងជួរឈរនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) នោះមានន័យថាត្រូវមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតអោយនាំចូល ឬលិខិតគតិយុត្តិប្រហាក់ប្រហែលពីក្រសួង ស្ថាប័ន ឬអង្គភាពជំនាញមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

៣- ចំពោះប្រព្រឹត្តកម្មលេខរៀងទី (4) (5) និង (6) គឺជាប្រព្រឹត្តកម្មហាមឃាត់ដាច់ខាត មិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នជាក់លាក់ណាមួយឡើយ ហើយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជា។

*********************